ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងផែនការ**
លេខ.០៤៨៦... ផក

ថ្ងៃ ៨ ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២០

# ជម្រាបជូន
# ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរផែនការ រាជធានី ខេត្ត

**កម្មវត្ថុ**: គ្រប់គ្រងភាពមិនប្រក្រតីក្នុងការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**យោង**: - សេចក្តីសម្រេច លេខ០២៦ ហសវ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចរៀបចំ និង គ្រប់គ្រងយន្តការជំនួយសង្គមក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

-អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ជូនភ្ជាប់**: - សេចក្តីណែនាំស្តីពីនីតិវិធីនៃការមិនជ្រើសរើសសម្ភាសន៍ និងការដកគ្រួសារពីបញ្ជីគ្រួសារក្រីក្រ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរផែនការរាជធានី ខេត្ត** ជ្រាបថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា គឺមានគោលបំណងដើម្បីរក្សាលំនឹងជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និង គ្រួសារងាយរងគ្រោះដែលមានបណ្ណសមធម៌មានសុពលភាពទទួលបានពីការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមជុំធម្មតា និង ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលប្រយុទ្ធជំងឺកូវីដ-១៩។ បន្ទាប់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានអនុវត្តក្នុងរយៈពេលពីរសប្តាហ៍កន្លងមកនេះ ខ្ញុំសង្កេតឃើញមានបញ្ហាមួយចំនួនដូចខាងក្រោមកំពុងកើតមានឡើង៖

- គ្រួសារមួយចំនួនកាន់បណ្ណសមធម៌ដែលហួសសុពលភាព,
- គ្រួសារមួយចំនួនមានបណ្ណសមធម៌មានជីវភាពប្រសើរ,
- គ្រួសារក្រីក្រមួយចំនួននៅពុំទាន់មានបណ្ណសមធម៌, និង

- គ្រួសារមួយចំនួនចាប់ផ្តើមបំបែកសមាជិកដើម្បីបង្កើតគ្រួសារថ្មីបំណងទទួលបានបណ្ណសមធម៌។

សេចក្តីដូចបានជម្រាបជូនខាងលើ និង ដើម្បីធានាបាននូវគុណភាពទិន្នន័យ និង តម្លាភាពជូនគ្រួសារក្រីក្រសម្រាប់ទទួលបានសាច់ប្រាក់ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាលកម្ពុជា នេះ **ប្រធានមន្ទីរផែនការរាជធានី ខេត្ត** ត្រូវអនុវត្តកាតព្វកិច្ចមួយចំនួន ដូចខាងក្រោម៖

- សហការជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិសម្រាប់ផ្តល់ការណែនាំពីនីតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលប្រយុទ្ធជំងឺកូវីដ-១៩។
- សហការ និង ចុះដល់មូលដ្ឋាន ជាពិសេស ឃុំ សង្កាត់ ដើម្បីណែនាំដល់គ្រួសារដែលកំពុងប្រើបណ្ណសមធម៌ដែលហួសសុពលភាព។
- សហការ និង ចុះដល់មូលដ្ឋាន ជាពិសេស ឃុំ សង្កាត់ ដើម្បីណែនាំ និង ដកបណ្ណសមធម៌មានជីវភាពប្រសើរ។
- សហការ និង ចុះដល់មូលដ្ឋាន ឃុំ សង្កាត់ ដើម្បីណែនាំ និង ពិនិត្យការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រដែលនៅពុំទាន់មានបណ្ណសមធម៌។
- សហការ និង ចុះដល់មូលដ្ឋានដោះស្រាយភាពមិនប្រក្រតី និង ការតវ៉ា នានា។

អាស្រ័យហេតុនេះ សូម **ប្រធានមន្ទីរផែនការរាជធានី ខេត្ត** ជ្រាប និង ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានមន្ទីរផែនការរាជធានី ខេត្ត** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

<u>ចម្លងជូន:</u>
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ឯកសារ